ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងរដ្ឋប្បវេណី

លេខ: ០១៩

ចុះថ្ងៃទី ១៦-១-២០១៣

សាលដីកា

លេខ: ០៨ក្រ៕

ចុះថ្ងៃទី ១៥-៣-២០១៣

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នាថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៣

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

ឯកឧត្តម [redacted] ជាប្រធាន

ឯកឧត្តម [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**ក្រឡាបញ្ជី**

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើសំណុំរឿងរដ្ឋប្បវេណីលេខ ០១៩ ចុះថ្ងៃទី ១៦-១-២០១៣ រវាង :

-ដើមចោទឈ្មោះ [redacted] ហ្សេីឌី ភេទប្រុស អាយុ៣០ឆ្នាំ ជាតិខ្មែរ មុខរបរមន្ត្រីអាជ្ញាធរអប្សរា ទីលំនៅសព្វថ្ងៃនៅភូមិខ្នា ឃុំជ្រាវ ក្រុងសៀមរាប ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] គីមហ៊ួន -រ- ម្តាយឈ្មោះ [redacted] អ៊ី -រ- ប្រពន្ធឈ្មោះ [redacted] លីណា មានកូន៣នាក់ ។

-ចុងចម្លើយឈ្មោះ [redacted] តៃ ភេទប្រុស អាយុ៦៣ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃនៅភូមិប្រម៉ាត់ដី ឃុំស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted] ទូច -ស- ម្តាយឈ្មោះ [redacted] សៀង -ស- ប្រពន្ធឈ្មោះ [redacted] ឡូត មានកូន៩នាក់

**ខ្លឹមសារនៃការទាមទាររបស់ដើមចោទ**

១-ការទាមទាររបស់ដើមចោទ :

-ដើមចោទបានប្តឹងថា សុំអោយតុលាការចេញសាលក្រមដូចខាងក្រោម :

-សុំទាមទារប្រាក់ជំពាក់ចំនួន ៤.៤០០ដុល្លា " បួនពាន់បួនរយដុល្លា " និងការប្រាក់៣%ក្នុងមួយខែ ។

-ថ្លៃខាតបង់ពេលវេលានិងជម្ងឺចិត្តចំនួន ៤លានរៀល ។

-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។





Scanned with CamScanner

## អង្គហេតុ និងចំណុចវិវាទ

ឈ្មោះ[redacted]តៃ បានខ្ចីលុយពីឈ្មោះ[redacted]ហេរ៉ីឌី ចំនួន៣លើក ដែលមានធ្វើកិច្ចសន្យាដូចខាងក្រោម :

-កិច្ចសន្យាលើកទី១ ចុះថ្ងៃទី ៨-៦-២០១០ ខ្ចីប្រាក់ចំនួន ២០០០ដុល្លា ។

-កិច្ចសន្យាលើកទី២ ចុះថ្ងៃទី ៩-៦-២០១០ ខ្ចីប្រាក់ចំនួន ២០០០ដុល្លា ។

-កិច្ចសន្យាលើកទី៣ ចុះថ្ងៃទី ២៥-៦-២០១០ ខ្ចីប្រាក់ចំនួន ៤០០ដុល្លា ។

សរុបទឹកប្រាក់ដែលខ្ចីចំនួន ៤.៤០០ដុល្លា ដើម្បីរកស៊ីទិញលក់ដីហ៊ុនគ្នា បានផលចំណេញចែកគ្នា ជាមួយឈ្មោះ[redacted]ឆងអ៊ី និងឈ្មោះ[redacted] លីណា ជាប្រពន្ធដើមចោទឈ្មោះ[redacted] ហេរ៉ីឌី ។ ដោយពេល នោះម្ចាស់ដីឈ្មោះ[redacted]សុត្រ គេទាមទារអោយកក់ចំនួន១ម៉ឺនមួយពាន់ដុល្លា តែចុងចម្លើយឈ្មោះ[redacted] តៃ គាត់គ្មានលុយដាក់ហ៊ុន និងគេក៏ធ្វើកិច្ចសន្យាផ្តិតមេដៃខ្ចីពីឈ្មោះ[redacted]ហេរ៉ីឌី ទាំង៣លើកគ្រប់ ពេលដែលត្រូវប្រគល់លុយអោយឈ្មោះ[redacted] សុត្រ ទាំងបីលើកដែរ ។ តែក្រោយពីពេលលក់ដីមកម៉ូយ ចិនដែលគេថា គេមកទិញដីនោះគេមិនបានមកទេ រហូតដល់សព្វថ្ងៃដែលធ្វើអោយប្រាក់កក់ដាច់ទៅលើ ម្ចាស់ដីទើបឈ្មោះ[redacted] ហេរ៉ីឌី ប្តឹងទាមទារប្រាក់ដែលឈ្មោះ[redacted] តៃ ខ្ចីនោះមកវិញ ព្រមទាំងការប្រាក់ ៣%មួយខែ និងទាមទារជម្ងឺចិត្តចំនួន៤លានរៀលផង ។

## ការអះអាងរបស់គូភាគី

-ដើមចោទឈ្មោះ[redacted]ហេរ៉ីឌី តំណាងដោយឈ្មោះ[redacted] លីណា ( វត្តមាន )

-ចុងចម្លើយឈ្មោះ[redacted]តៃ ( អវត្តមាន )

-ដើមចោទឈ្មោះ[redacted] ហេរ៉ីឌី តំណាងដោយឈ្មោះ[redacted]លីណា បានថ្លែងការណ៍ថា ខ្លួនមិនសុខចិត្តនឹងសាលក្រមត្រង់ចំណុចការប្រាក់៥% ក្នុងមួយឆ្នាំ និងចំណុចខាតបង់ពេលវេលាចំនួន ២.៥០០.០០០រៀល ហើយខ្លួនសុំទាមទារអោយចុងចម្លើយសងជម្ងឺចិត្ត៤លានរៀល និងការប្រាក់៣% ក្នុងមួយខែវិញ ដូចក្នុងពាក្យបណ្តឹងដដែល ។ ។

-ចុងចម្លើយឈ្មោះ[redacted]តៃ បានទទួលដីកាកោះតាំងពីថ្ងៃទី៤-៣-២០១៣ ហើយ តែមេធាវីតំណាងដោយអាណត្តិ បានមកសុំលើកពេលសវនាការ នៅពេលទាញហេតុផលដោយផ្ទាល់មាត់ ។

## សំអាងហេតុ

យល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍របស់ឈ្មោះ[redacted] តៃ (ចុងចម្លើយ) ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១១ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ១៤ "ឆ" ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នា២០១១ ត្រង់ចំណុចសេចក្តីសម្រេចទាំងមូល នៃសាលក្រមសាលាដំបូងខេត្តកំពង់ធំ ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះ យកមកជំនុំជម្រះបានតាមច្បាប់ ។

២-បណ្តឹងឧទ្ធរណ៍របស់ឈ្មោះ[redacted] ហេរ៉ីឌី (ដើមចោទ)លេខ ០១ ចុះថ្ងៃទី ៣ ខែ មករា ឆ្នាំ២០១២ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីលេខ ១៤ "ឆ" ចុះថ្ងៃទី ៧-១២-២០១១ របស់សាលាដំបូងខេត្តកំពង់ធំ ត្រង់ចំណុចទី៣និងទី៤ នៃសេចក្តីសម្រេចបញ្ចប់របស់សាលក្រម ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍អាចលើករឿងនេះ យកមកជំនុំជម្រះបានតាមច្បាប់ ។



Scanned with CamScanner

៣-ពេលទាញហេតុផលដោយផ្ទាល់ ដើមចោទបានធ្វើសេចក្ដីថ្លែងការថា ខ្លួននៅតែប្ដឹងទាវដូចក្នុងពាក្យបណ្ដឹងឧទ្ធរណ៍របស់ខ្លួនមិនសុខចិត្តត្រង់ចំណុចទី៣និងទី៤ នៃសេចក្ដីសម្រេចនោះ ដូចជាចំណុចការប្រាក់៣%ក្នុងមួយខែ តុលាការបែរជាសម្រេចអោយសង៥% ក្នុងមួយឆ្នាំវិញ ហើយការខូចខាត ខ្លួនសុំទាមទារអោយចុងចម្លើយសងចំនួន ៤លានរៀល តុលាការអោយសងចំនួន ២.៥០០.០០០រៀល ទៅវិញ ដោយខ្លួនខាតពេលវេលា អស់ច្រើនណាស់ ។

៤-ការដែលសាលាដំបូងខេត្តកំពង់ធំ បានលើកសំអាងហេតុនោះ មានលក្ខណៈត្រឹមត្រូវ ហើយគប្បីសាលាឧទ្ធរណ៍ ឯកភាពជាមួយសំអាងហេតុទាំងអស់នោះ ដោយសាលាឧទ្ធរណ៍ពុំចាំបាច់លើកយកសំអាងហេតុដដែលៗមកទៀតទេ ។

៥-ចុងចម្លើយឈ្មោះ [redacted] តែ បានទទួលដីកាកោះគាំងពីថ្ងៃទី ៤-៣-២០១៣ ហើយមេធាវីតំណាងដោយអាណត្តិអោយឈ្មោះ [redacted] តែ បានសុំលើកសវនាការចុះថ្ងៃទី ១៤-៣-២០១៣ ហើយបើគិតពីរយៈពេលចុងចម្លើយ បានទទួលដីកាកោះគាំងពីថ្ងៃទី ៤-៣-២០១៣ ហើយពេលវេលាគ្រប់គ្រាន់ពឹងពាក់មេធាវី សាលាឧទ្ធរណ៍ពុំអាចលើកពេលសវនាការបានឡើយ ដើម្បីកុំអោយអូសបន្លាយនីតិវិធី ។

៦-សាលក្រមរដ្ឋប្បវេណីលេខ ១៤-ធ- ចុះថ្ងៃទី ៧-១២-២០១៣ របស់សាលាដំបូងខេត្តកំពង់ធំ មានលក្ខណៈត្រឹមត្រូវហើយតាមទំរង់និងគតិច្បាប់ គប្បីសាលាឧទ្ធរណ៍តម្កល់សាលក្រមនេះទុកជាបានការ ។

## ទនិច្ឆ័យសេចក្ដី

១-ច្រានចោលបណ្ដឹងឧទ្ធរណ៍របស់ [redacted] តែ ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១១ ចោល ។

២-ច្រានចោលបណ្ដឹងឧទ្ធរណ៍ របស់ឈ្មោះ [redacted] ហ៊ឿឌី ចុះថ្ងៃទី ៣-១-២០១២ ចោល ។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៤ -ធ- ចុះថ្ងៃទី ៧-១២-២០១១ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការពេញទាំងមូល ។

៤-ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់ឈ្មោះ [redacted] តែ និងឈ្មោះ [redacted] ហ៊ឿឌី ។

៥-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី ១៥-៣-២០១៣ បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|

ហត្ថលេខា [redacted]

---

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានចំលងត្រឹមត្រូវតាមច្បាប់ដើម
ភ្នំពេញថ្ងៃទី20 ខែ ៣ ឆ្នាំ២០13..
ក្រឡាបញ្ជី

[redacted]